# រឿង មហាចោរនៅទល់ដែន

## ភាគទី៣២ (ព្រះនាងខត្តិយាណី)

កាមាប្រឹងទប់សំដីទ្រគោះឡូកឡឺយនេះ រួចសំឡឹងឡោះងតឹងស្ទើរប្រាលពីដើមទ្រូងថា: ហ៊ឹស! ហ៊ឹស! កាមាមិនងាយស្លាប់ទេ។ កាមារស់នៅដើម្បីសងសឹកឈ្មោះមានន្ទ។ មើល។ នែមានន្ទទុស្នាមមុខ ស្នាមដៃឲ្យកាមាសងឈាមដែលបានហូរចេញពីសាច់កាមា។ ឈាមនេះបានហូរនៅថ្មីៗ សើមៗ ក្ដៅៗ។ ឈាមនេះមួយតំណក់ ស្រែកហៅឈាម មានន្ទមួយតំណក់ដែរ។ ឈាមនេះហៅឲ្យកាមាសងសឹក។ អឺ! សេចក្ដីសងសឹកជាចិត្តមួយមុខដូចចិត្តស្នេហា។ គេនឹកឃើញរាល់ពេល។ គេសង្ឃឹមរាល់ថ្ងៃ។ គេទន្ទឹងចាំវេលារាល់នាទី។ គេចងគេចាំជានិច្ច....ឃើញទេបង! ហ៊ឺៗ ឃើញទេ ហ៊ឺ!

កាមាញញញ្ញើញ ទះកំផ្លៀងមានន្ទមួយដៃផូងយ៉ាងអស់ទំហឹង។ មានន្ទដួលផ្កាប់ផ្ការ ស្ទុះក្រោកឡើងកញ្ជ្រោលក្នុងកណ្ដាប់ដៃទាហានទាំងបួនដែលចាប់អ្នកជាប់ រួចស្រែកយ៉ាងសាហាវលាន់រំពងគុកថា: កាមា! កាមា! យើងទាំងពីរនៅទល់មុខនឹងមុខ ខ្លួននឹងខ្លួន។ លែងដៃ លែងជើងអញចេញ ទើបអញហៅគ្រាន់បើ។ កាមា! កាមា! សាច់និងសាច់ ឈាមនិងឈាម គំនុំនិងគំនុំ កុំចាំរើសពេល កុំចាំរើសថ្ងៃ កុំចាំរើសម៉ោង មកចុះមកឥឡូវនេះ។ លែងៗ ឆាប់ៗ។

ពីមុខមានន្ទដែលកញ្ជ្រោលដូចខ្លាជាប់អន្ទាក់ កាមាញញឹមរួចកាន់ឫកពារនឹងខ្លួន សំឡេងណែនស្មើដដែល ហាក់ដូចគ្មានបានធ្វើអ្វី ឆ្លើយទៀតថា:

ហ៊ឹសៗ មរណភាពរបស់មានន្ទនៅក្នុងកណ្ដាប់ដៃកាមាហើយ។ កាមាមិនលែងមានន្ទដាច់ខាត។ អយុត្តិធម៌មានជ័យរហូតតាំងពីថ្ងៃនេះទៅ ដោយមានន្ទម្នាក់ស្លាប់បង់ជីវិត។ ក្នុងពេលនេះគឺមានន្ទដែលហែលក្នុងទឹកភ្នែក ក្នុងឈាមក្នុងញើសរបស់អ្នកស្រុកដែលមានន្ទចង់ជួយស្រោចស្រង់។ កាមាប្ដេជ្ញាថាសម្លាប់ឲ្យអស់មនុស្សសុច្ចរិតប្រឆាំងនឹងធម្មជាតិល្បងមើល។ ឥឡូវអញ្ជើញបងមានន្ទហៅយុត្តិធម៌ ហៅព្រលឹងចិត្តស្នេហាជាតិហៅសេចក្ដីស្នេហាប្រជាជន មកជួយឲ្យខ្ញុំឃើញពិស្ដារផងមើល។ ទេ! គ្មានទេ ឃើញទេគ្មានជួយទេ។ យុត្តិធម៌ឯកពជ្យជាតិ ឥស្សរភាពកើតបានតែនឹងអាវុធ។

អត្ថបទដោយ៖ មាស សុភាព

*ចុងដាវរបស់កាមាគ្រវីយ៉ាងក្វៃតៗ នៅចុងដង្ហើមមានន្ទដែលខាំធ្មេញសង្រ្កឹតហើយដែលសម្រុក ឲ្យរួចពីដៃទាហានទាំងបួនដែលអ្នកចាប់អ្នក។ កាមាបន្តការចរចាដូចតទៅ: អឺ! អាវុធនេះសាងឲ្យកើតសេចក្តីស្ងប់ស្ងាត់បាន។ អាវុធនេះធ្វើឲ្យមនុស្សរាប់លាន់ឱនក្បាលបានមិនថាស្រី ប្រុស ក្មេង ចាស់ទេ។ ឥឡូវកាមាចង់ឲ្យមានន្ទអោនក្បាល ពីមុខអាវុធរបស់កាមា។ កាមារុញដាវទៅមុខ បម្រុងនឹងចាក់មានន្ទសម្លាប់ចោល។ តែមានន្ទចាប់ដាវនេះកន្ត្រាក់របូតពីក្នុងដៃ។ មានន្ទយកដាវនេះមកកាច់នឹងក្បាលជង្គង់បាក់ជាពីរកំណាត់ប្រស់ រួចគ្រវាត់ទៅកៀនជញ្ជាំងប្រាវ និយាយបន្ទរសំឡេងថា:*

*កាមា! កាមា! អញចង់ឲ្យដាវទាំងអស់ក្លាយទៅជាគ្រឿងសំរាប់ការពារប្រជាជនរាប់លាននាក់។ អញចង់ឲ្យដាវទាំងអស់បាក់ចំពោះមុខប្រជាជនមិនថាចំពោះមុខស្រី ឬប្រុស ក្មេង ឬចាស់ទេ។ អញចង់ឲ្យអ្នកកាន់ អំណាចទាំងអស់ ឱនក្បាលពីមុខច្បាប់។ អញចង់ឲ្យជនជាតិនីមួយៗគ្រប់គ្រងដោយខ្លួនឯងលើដែនដី។*

*កាមាកញ្ឆក់យកដាវមួយទៀត ពីចង្កេះទាហានម្នាក់មកផ្តោតដើមទ្រូងមានន្ទម្តងទៀត។ អាំ! អាំ! បងដឹងអានុភាពរបស់អាវុធដែលគ្រប់គ្រងស្រុកហើយ។ ទៅៗ! ស្លាប់ទៅចុះ! (កាមារុញដាវទៅមុខយ៉ាងអស់ទំហឹង)*

*សម្រែកនារីម្នាក់ស្រែកយ៉ៃឡើង: អេ! ឈប់ៗបងកាមា បង! កុំៗ កុំទាន់អាល...កាមាទុចង៉ក់មានន្ទក្រឡេកមើលទៅឃើញនារីម្នាក់រត់ចូលមក។ នាងមានរាងស្តើងខ្ពស់សាច់ម៉ដ្ឋស្បៀកពាក់ល្អផុតអស់នារីទាំងពួងមានគ្រឿងអលង្ការលំអនៅក និងនៅដៃ ដាំសុទ្ធសឹងពេជ្រទាំងគ្រាប់ភ្លឺចិញ្ចែង។*

*នារីមានសម្ផស្សក្រៃពេកជាទីគួរប្រតិព័ទ្ធ។ នាងទេវីល្អមួយបែបនាងដែលទើបមកដល់ល្អមួយបែបថ្មីប្លែកទៅទៀត។ ទាហានទាំងអស់ឱនគោរពស្ត្រីថ្មីដែលហក់ស្ទុះចុះពីរាជបល្ល័ង្កព្រហ្មមកក្នុងពេលដែលបងប្អូនពីរនាក់ហៀបនឹងសម្លាប់គ្នា។ នាងងក់ក្បាលគំនាបយ៉ាងគួរសមដល់ទាហានវិញ។ ធីតាជណ្តើរមកឱបចង្កេះកាមា។*

*អត្ថបទដោយ៖ មាស សុភាព*

បង! កុំធ្វើដូច្នោះ បងប្អូនយើងទេ។ ប្អូនសូមអង្វរចុះ។ ប្អូនមកដល់ទីនេះយូរណាស់ហើយ ប្អូនលបមើលតាមមាត់ទ្វារមក។ ប្អូនបង្ហូរទឹកភ្នែក។

នារីបេះដាវពីដៃកាមា។ ទឹកមុខដ៏វិចិត្រដូចស្រីស្ពានសួគ៌សំឡេងដ៏ពិរោះដូចតូរតន្ត្រីនាស្ពានតាវតឹង្ស សាច់ទន់ត្រជាក់ ភ្នែករលោងដែលអង្វរនេះធ្វើឲ្យកាមាទន់ដៃជើងអស់ស្មើរបាត់ស្មារតី។ បុរសស្តាប់នាងផ្អឹង។ ភ្នែកទល់ភ្នែក កាមាហាក់ឃើញវិញ្ញាណនាងផុះក្នុងវិញ្ញាណអ្នក។

កាមានិយាយឆ្លើយមុខស្លួតស្មើរខ្សឹបថា:

អូន! មិនត្រូវមកទីនេះទេ ត្បិតនេះគេហាម។ ម្យ៉ាង ទីនេះជាទីដែលអាចមានគ្រោះថ្នាក់ដល់អូន។ នាងឱបខ្ទប់ក្បាលទៅក្នុងដើមទ្រូវកាមា និយាយយ៉ាងខ្សឹកខ្សួលថា:

បងមានប្រសាសន៍ត្រូវណាស់ តែប្អូនមានចិត្តនឹករលឹកបន្ទាយយើងនេះណាស់។ ប្អូនខានមកប្រាំពីរឆ្នាំហើយ។ បងគិតមើល ប្អូននឹកនោះប៉ុណ្ណោះ។ ប្អូននៅក្នុងបន្ទប់របស់ប្អូនមិនបានទេចង់តែដើរទៅមើល។ ប្អូនហាក់ឃើញរឿងចាស់ៗ ដែលប្អូនធ្លាប់រស់នៅពីដើម។ គឺបងទេដែលមិនត្រូវមកទីនេះសោះ។

កាមាឆ្លើយថា: ម៉េចក៏ដូច្នោះ? ធីតាងើបមើលមុខកាមាគ្រវីក្បាលឆ្លើយថា:

ព្រោះទីនេះ ជាទីក្តៅក្រហាយដែលអាចនាំចិត្តបងឲ្យអន្ទះអន្ទែងដៃឡអាចនាំដៃបងឲ្យប្រឡាក់នៅឈាមមួយដែលមិនហួសពីឈាមរបស់បងហើយដែលជាឈាមរបស់ប្អូនដែរ។ បើបងស្រលាញ់ប្អូនមែនៗ សូមបងអញ្ជើញទៅវិញ។

(សូមរង់ចាំតាមដានភាគទី៣៣ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព